Statewide Processing Center
PO Box 14620
Salem, OR  97309

P.O. Box 14015, Salem, OR  97309
Voice: 1-800-699-9075
FAX: 503-378-5628
TTY: 711
www.ohp.oregon.gov

September 2022

Case number:

# រក្សាព័ត៌មានទំនាក់ទំនងរបស់អ្នកបច្ចុប្បន្ន ដើម្បីទទួលបានជំនួយរបស់អ្នក។

សូមគោរពជូនសមាជិកគម្រោងសុខភាពរដ្ឋអូរិហ្គិន!

ការផ្តល់ជូនពីគម្រោងសុខភាពរដ្ឋអូរិហ្គិន (OHP) របស់អ្នកមិនផ្លាស់ប្តូរទេ! សំបុត្រនេះគឺនិយាយអំពីជំហានដែលអ្នកគួរធ្វើ ដើម្បីទទួលបានការធានារ៉ាប់រងរបស់អ្នកនាពេលអនាគត។

## របៀបរក្សាព័ត៌មានទំនាក់ទំនងរបស់អ្នកបច្ចុប្បន្ន៖

1. **អនុញ្ញាតឱ្យពួកយើងដឹងភ្លាមៗ នៅពេលដែលអាសយដ្ឋានផ្ទះ អ៊ីមែល អាសយដ្ឋានអ៊ីមែល ឬលេខទូរស័ព្ទរបស់អ្នកផ្លាស់ប្តូរ។** សូមអានទំព័រទី 2 សម្រាប់វិធីរាយការណ៍ការនូវការផ្លាស់ប្តូរ។
2. **បើកសំបុត្ររបស់អ្នក ហើយអានការជូនដំណឹងដែលយើងផ្ញើអោយ។** តែងតែផ្ញើមកយើងនូវព័ត៌មានដែលយើងស្នើសុំ។
3. **តាមដានព័ត៌មានថ្មីៗរបស់ OHP ។** ចូលទៅកាន់ **OHP.Oregon.gov** ឬសួរអង្គការដៃគូក្នុងសហគមន៍ OHP ក្នុងតំបន់របស់អ្នក។ រកបាននៅ **bit.ly/ohplocalhelp**។

## អ្វីដែលអ្នកត្រូវដឹង៖

### 1. ការធានារ៉ាប់រងពី OHP របស់អ្នកនៅតែមាន។

អ្នកមិនចាំបាច់ឆ្លើយតបទៅនឹងលិខិតនេះទេ។ ប្រសិនបើយើងត្រូវការព័ត៌មានបន្ថែម យើងនឹងប្រាប់អ្នកឱ្យដឹង — ដរាបណាយើងមានព័ត៌មានទំនាក់ទំនងបច្ចុប្បន្នរបស់អ្នក។

**2. ការផ្លាស់ប្តូរនាពេលខាងមុខចំពោះ OHP បន្ទាប់ពីមានជំនួយគ្រាអាសន្ននៃកូវីដ 19៖**

ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ 19 សមាជិកភាគច្រើនបានរក្សា OHP របស់ពួកគេដដែល បើទោះបីជាពួកគេមានការផ្លាស់ប្តូរក្នុងជីវិតរបស់ពួកគេ ដូចជារកបានប្រាក់បន្ថែមក៏ដោយ។ នេះគឺដោយសារតែការផ្លាស់ប្តូរគោលនយោបាយនៅក្រោមជំនួយគ្រាអាសន្ននៃកូវីដ 19។

**3. បន្ទាប់ពីស្ថានភាពអាសន្នកូវីដ 19 បញ្ចប់៖**

យើងនឹងទាក់ទងទៅអ្នក ប្រសិនបើយើងត្រូវការព័ត៌មានបន្ថែម ដើម្បីដឹងថាតើអ្នកនៅតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួល OHP ដែរឬទេ។

យើងចង់ជួយអ្នកឱ្យត្រៀមខ្លួនមុនពេលដែលយើងសួររក។ ប្រសិនបើយើងមិនអាចទាក់ទងទៅអ្នកបានទេ អ្នកអាចបាត់បង់ការធានារ៉ាប់រងរបស់អ្នក។ ការរក្សាព័ត៌មានទំនាក់ទំនងរបស់អ្នកបច្ចុប្បន្ន ជួយអ្នកឱ្យរក្សាការរ៉ាប់រង។

## របៀបរាយការណ៍នូវការផ្លាស់ប្តូរ

អ្នកអាចរាយការណ៍នូវការផ្លាស់ប្តូរតាមវិធីជាច្រើន៖

**ទាក់ទងទៅអង្គការផ្តល់កិច្ចគាំពារសម្របសម្រួលរបស់អ្នក (CCO)**

នេះគឺជាអង្គការដែលគ្រប់គ្រង OHP របស់អ្នក។

- អ្នកអាចកំណត់អត្តសញ្ញាណ CCO របស់អ្នក បានដោយមើលអត្តសញ្ញាណប័ណ្ណសមាជិករបស់អ្នក។
- ស្វែងរកព័ត៌មានទំនាក់ទំនងរបស់ CCO របស់អ្នកតាមរយៈ៖ **bit.ly/ccoplans**។

**អនឡាញ**

benefit.oregon.gov

បង្កើតគណនីមួយ ឬចូលទៅក្នុងគណនីដែលមានស្រាប់របស់អ្នក។

មានសរសេរជាភាសាអង់គ្លេស ឬភាសាអេស្ប៉ាញ។

**តាមទូរស័ព្ទ៖**

មជ្ឈមណ្ឌលផ្តល់សេវាកម្មបំរើអតិថិជន

- 1-800-699-9075 (TTY 711)
- ថ្ងៃច័ន្ទ ដល់ សុក្រ ពីម៉ោង 7 ព្រឹក ដល់ 6 ល្ងាច ម៉ោងតំបន់ប៉ាស៊ីហ្វិក។
- អាចរកបានអ្នកបកប្រែភាសា។
- អ្នកក៏អាចទទួលបានអ្នកបកប្រែភាសាដែលអ្នកនិយាយ មុនពេលពិភាក្សាជាមួយបុគ្គលិកបាន។ ចុចរកភាសានៅ benefit.oregon.gov។

**ជួបដោយផ្ទាល់ ឬជួបតាមទូរស័ព្ទ៖**

ក្រសួងបំរើមនុស្សចាស់ និងជនពិការ, កម្មវិធីជួយគ្រប់គ្រាន់ដោយខ្លួនឯង ឬទីភ្នាក់ងារតំបន់ នៅក្នុងក្រសួងបំរើមនុស្សចាស់

- ស្វែងរកទីតាំង និងលេខទូរស័ព្ទនៅ **Oregon.gov/DHS/Offices** ។
- សូមទូរស័ព្ទមកមុននឹងទៅក្រសួង។
- អាចរកអ្នកបកប្រែភាសាបាន។

សូមអរគុណ!

គម្រោងសុខភាពនៃរដ្ឋអូរីហ្គិន

អ្នកអាចទទួលបានសំបុត្រនេះជាភាសាផ្សេងទៀត ជាការបោះពុម្ពអក្សរធំ អក្សរសំរាប់មនុស្សពិការភ្នែក ឬជាទម្រង់ដែលអ្នកចង់បាន។ អ្នកក៏អាចស្នើសុំរកអ្នកបកប្រែភាសាបានផងដែរ។ ជំនួយនេះគឺឥតគិតថ្លៃទេ។ សូមទូរស័ព្ទទៅលេខ 800-699-9075 ឬ TTY 711។ យើងទទួលយកការហៅបញ្ជូនបន្ត។